**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

លេខ: ៥០៨៨ ប្រក

**ក្រសួងការងារ**
**និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# ប្រកាសអន្តរក្រសួង
# ស្តីពី
# នីតិវិធី និងបែបបទ នៃការចេញ ការដកហូត ការបដិសេធ លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**រដ្ឋមន្ត្រីក្រសួងការងារ**
**និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ ស្តីពីលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស
- យោងតាមសំណូមពរចាំបាច់នៃការងារ។

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីនីតិវិធី និងបែបបទ នៃការចេញ ការដកហូត ការបដិសេធ និងការធ្វើមោឃភាពលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស សំដៅបង្កភាពងាយស្រួលដល់ពលករកម្ពុជាទទួលបានឯកសារ សម្រាប់ធ្វើដំណើរឆ្លងដែនពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសដែលពលករកម្ពុជាទទួលការអនុញ្ញាតឱ្យស្នាក់នៅ និងធ្វើការជាផ្លូវការ។

**ប្រការ ២.-**

ពលករកម្ពុជាទៅធ្វើការផ្លូវការនៅបរទេស សំដៅដល់ពលករដែលមានកិច្ចសន្យាការងារ ដែលបញ្ជាក់ទទួលស្គាល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្របច្បាប់ជាធរមាន។

**ប្រការ ៣.-**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈប្រគល់ភារកិច្ចជូនអគ្គនាយកដ្ឋានការងារ ក្រសួងមហាផ្ទៃប្រគល់ភារកិច្ចជូនអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ដើម្បីរៀបចំយន្តការការងារក្នុងទីតាំងរួមជាមួយគ្នានៅរាជធានីភ្នំពេញ និងបណ្តាខេត្តមួយចំនួនតាមការចាំបាច់ក្នុងការចេញឯកសារបញ្ជាក់ទទួលស្គាល់ពលករកម្ពុជាធ្វើការងារនៅបរទេស ប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស និងបំពេញបែបបទផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសជូនពលករកម្ពុជា។

អគ្គនាយកដ្ឋានការងារ និងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវចាត់តាំងមន្ត្រីជំនាញឱ្យទៅបំពេញភារកិច្ចនៅទីតាំងដែលនឹងត្រូវរៀបចំ។

**១. មន្ត្រីជំនាញអគ្គនាយកដ្ឋានការងារ មានភារកិច្ច៖**

- ពិនិត្យ និងសម្រេចក្នុងការចេញឯកសារបញ្ជាក់ទទួលស្គាល់ពលករកម្ពុជាធ្វើការនៅបរទេស និងប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេសជូនពលករកម្ពុជា
- ផ្តល់បង្កាន់ដៃជូនពលករសម្រាប់ការទទួលយកប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស
- រៀបចំសំណុំបែបបទស្នើសុំលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ជូនពលករកម្ពុជាបន្ទាប់ពីទទួលសំណុំឯកសារពីទីភ្នាក់ងារជ្រើសរើសឯកជន ដើម្បីបញ្ជូនទៅមន្ត្រីជំនាញរបស់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ។

**២. មន្ត្រីជំនាញអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មមានភារកិច្ច៖**

- ពិនិត្យ និងសម្រេចក្នុងការផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសជូនពលករកម្ពុជាតាមសំណុំឯកសារស្នើសុំរបស់មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានការងារ
- បំពេញសំណុំបែបបទស្នើសុំផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស
- បញ្ជូនទិន្នន័យដែលបំពេញរួចទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មដើម្បីបោះពុម្ពលិខិតធ្វើដំណើរ
- ផ្តល់បង្កាន់ដៃជូនពលករសម្រាប់ការទទួលយកលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស។

**ប្រការ៤.-**

ដើម្បីទទួលបានលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ពលករត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ
- សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតច្បាប់ដើម (ក្នុងករណីប្រើប្រាស់សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ត្រូវភ្ជាប់ជាមួយនូវសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬលិខិតបញ្ជាក់ទីលំនៅដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច ច្បាប់ដើម)
- កិច្ចសន្យាការងារ ដែលបញ្ជាក់ទទួលស្គាល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បំពេញសំណុំបែបបទសុំផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសដោយផ្ទាល់ ដូចជា បំពេញពាក្យស្នើសុំផ្តល់លិខិតធ្វើដំណើរ ផ្តិតខ្មៅម្រាមដៃ ចុះហត្ថលេខា ថតរូប វាស់កម្ពស់ យកភិនភាគស្លាកស្នាម និងសម្ភាស។

**ប្រការ ៥.-**

ប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស និងលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ត្រូវផ្តល់ជូនពលករកម្ពុជាដែលបានបំពេញបែបបទស្នើសុំរួច រយៈពេលមិនអោយលើស០៣ថ្ងៃ នៃថ្ងៃធ្វើការ។

ការបង់ថ្លៃសេវាសម្រាប់ទ្រទ្រង់ការងារចេញប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស និងការចេញលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសជូនពលករកម្ពុជា ជាបន្ទុករបស់ទីភ្នាក់ងារជ្រើសរើសឯកជន ។

កន្លែងបើកផ្តល់ប័ណ្ណពលករកម្ពុជាទៅធ្វើការនៅបរទេស និងលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស មានទីតាំងនៅរាជធានីភ្នំពេញ។

**ប្រការ ៦.-**

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវធ្វើការដកហូតរក្សាទុកលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសដែលបានផ្តល់ជូនពលករកម្ពុជា ក្នុងករណីដូចខាងក្រោម៖

- មានសំណើពីស្ថាប័នមានសមត្ថកិច្ចជំនាញពាក់ព័ន្ធ
- មានសេចក្តីសម្រេចពីស្ថាប័នតុលាការ
- អ្នកកាន់កាប់ប្រើប្រាស់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ជាពិរុទ្ធជន ទណ្ឌិត ឬជនមានដីកាកំពុងស្វែងរកចាប់ខ្លួន ឬកំពុងហាមឃាត់មិនឱ្យចេញក្រៅប្រទេស
- អ្នកកាន់កាប់ ប្រើប្រាស់មិនមែនជាពលរដ្ឋដែលមានសញ្ជាតិខ្មែរ។

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ត្រូវធ្វើការបដិសេធ ឬមោឃភាពចំពោះលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស ក្នុងករណីដូចខាងក្រោម៖

- មានសំណើពីស្ថាប័នមានសមត្ថកិច្ច
- លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសក្លែងក្លាយ

- លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសដែលបានបាត់។

**ប្រការ ៧.-**

ត្រូវទទួលទណ្ឌកម្មរដ្ឋបាល ឬ/និង ទទួលទោសតាមច្បាប់ជាធរមានចំពោះជនណាដែល៖

- ផ្តល់ព័ត៌មានខុសពីការពិតក្នុងសំណុំបែបបទសុំផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស
- ក្លែង កោស លុប ឬសរសេរត្រួតលើលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស
- មានចេតនាជួយសម្រួលសំណុំបែបបទ ឬសម្រេចផ្តល់លិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេសដល់ជនណាដែលមិនមែនជាពលករកម្ពុជាត្រូវទៅធ្វើការជាផ្លូវការនៅបរទេស។

**ប្រការ ៨.-**

ប្រកាសលេខ ៣៦៩៦ ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ ស្តីពីនីតិវិធី និងបែបបទនៃការចេញលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៩.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនានា នៃក្រសួងមហាផ្ទៃ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ ប្រធានអង្គភាពពាក់ព័ន្ធនានា នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១៧

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**រដ្ឋមន្ត្រីក្រសួងការងារ**
**និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៩
- ឯកសារ-កាលប្បវត្តិ